# ពរជ័យដ៏មានតម្លៃទាំងឡាយរបស់ព្រះអម្ចាស់

អែលឌើរ ខាល ប៊ី ប្រាត្ត
នៃក្រុមពួកចិតសិបនាក់

*កាលណាយើងបង់ដង្វាយមួយភាគក្នុងដប់របស់យើងដោយស្មោះត្រង់ នោះព្រះអម្ចាស់នឹងបើកទ្វារស្ថានសួគ៌ ហើយចាក់ព្រះពរដ៏មហិមាបំផុតមកលើយើង ។*

ខ្ញុំមានអំណរគុណចំពោះជីដូនជីតាដ៏សុចរិតដែលបានបង្រៀនដំណឹងល្អដល់កូនចៅខ្លួនក្នុងផ្ទះពីមុនមាននូវរាត្រីជួបជុំក្រុមគ្រួសារជាផ្លូវការ ។ ឪពុកម្ដាយ របស់ ម្ដាយ ខ្ញុំ មាន ឈ្មោះ អ៊ីដា ជេស្ពីសិន និង ចន អេ វ៉េធិន ។ ពួកគាត់រស់នៅក្នុងភូមិមួយដ៏តូចនៃ កូឡូនៀ ជូរ៉េហ្ស, ឆីហួអាហួអា ប្រទេស ម៉ិកស៊ិកូ ។ កូនរបស់គ្រួសារ វ៉េធិន ត្រូវបានបង្រៀនដោយការណែនាំ និងការសង្កេតនូវគំរូនៃឪពុកម្ដាយខ្លួន ។ នៅដើមទសវត្សរ៍ឆ្នាំ 1920 មានវិបត្តិក្នុងប្រទេស ម៉ិកស៊ិកូ ។ ការធ្វើបដិវត្តន៍ដ៏ឃោរឃៅទើបតែបានបញ្ចប់ ។ ការចរាចរសាច់ប្រាក់មានតិចតួចណាស់ ហើយភាគច្រើនគឺប្រើនូវកាក់ប្រាក់ ។ ជារឿយៗមនុស្សទូទៅបានធ្វើជំនួញខ្លួនតាមរយៈការជួញដូរ ឬការប្ដូរយករបស់និងសេវាកម្ម ។

មានថ្ងៃមួយនៅជិតចុងរដូវក្ដៅ លោកតា ចន បានត្រឡប់មកផ្ទះវិញដោយលក់អស់នូវគោមួយនឹម ហើយរកប្រាក់បាន 100 ផេសូ ជាកាក់ប្រាក់ ។ គាត់បានឲ្យប្រាក់ទៅលោកយាយ អ៊ីដា ដោយប្រាប់ថាប្រាក់នេះត្រូវប្រើសម្រាប់បង់ថ្លៃសាលារបស់កូនៗសម្រាប់បវេសនកាលថ្មីខាងមុខនេះ ។ លោកយាយ អ៊ីដា មានអំណរគុណចំពោះប្រាក់នោះ តែបានរំឭកលោកតា ចន ថាពេញមួយរដូវក្ដៅនេះពួកគាត់មិនបានបង់ដង្វាយមួយដប់សោះ ។ ពួកគេគ្មានចំណូលជាសាច់ប្រាក់ឡើយ តែលោកយាយ អ៊ីដា បានរំឭកគាត់ថា សត្វចិញ្ចឹមអាចផ្ដល់ជាសាច់ ស៊ុត និងទឹកដោះបាន ។ សួនដំណាំពួកគាត់បានផ្ដល់នូវផលផ្លែ និងបន្លែយ៉ាងច្រើន ហើយពួកគេបានធ្វើការដោះដូរផ្សេងទៀតយកជារបស់ តែពុំមែនជាប្រាក់ឡើយ ។

លោកយាយ អ៊ីដា បានណែនាំថា ពួកគាត់គួរផ្ដល់ប្រាក់នោះទៅឲ្យប៊ីស្សពសម្រាប់ដង្វាយមួយភាគដប់របស់ខ្លួន ។ លោកតា ចន រៀងអន់ចិត្តបន្តិចដោយសារប្រាក់នោះនឹងជួយយ៉ាងច្រើនដល់ថ្លៃសាលារបស់កូន តែគាត់បានយល់ព្រមភ្លាមៗថា ពួកគាត់ត្រូវបង់ដង្វាយមួយភាគដប់របស់ខ្លួន ។ គាត់បានយួរកាបូបដ៏ធំធ្ងន់នោះទៅការិយាល័យដង្វាយមួយភាគដប់ ហើយបង់ប្រាក់ដល់ប៊ីស្សព ។

មិនយូរប៉ុន្មានបន្ទាប់ពីនោះ គាត់បានដឹងថា មានបុរសជាអាជីវករម្នាក់មកពីសហរដ្ឋអាមេរិក គឺលោក ហាត់ នឹងអញ្ជើញមកដល់នៅសប្ដាហ៍ក្រោយអមដំណើរដោយអ្នកទីផ្សារមួយរូប ដើម្បីចំណាយពេលលំហែកាយដោយការដើរបាញ់សត្វ និងការស្ទូចត្រី ។

លោកតា ចន បានជួបនឹងបុរសទាំងនោះនៅឯស្ថានីយរថភ្លើងនៅជិត កូឡូនៀ ជូរ៉េហ្ស ។ គាត់មានសត្វសេះដែលដាក់កែបមួយហ្វូង និងមានសត្វពាហនៈសំខាន់ៗមួយហ្វូងទៀត ដែលត្រៀមខ្លួនជាស្រេចដើម្បីដឹកជញ្ជូនហឹប និងឧបករណ៍ដើម្បីធ្វើការបោះតង់នៅលើភ្នំ ។ នៅសប្ដាហ៍បន្ទាប់ គឺត្រូវបានចំណាយពេលដើម្បីជួយណែនាំផ្លូវដល់បុរសទាំងនោះ និងមើលខុសត្រូវលើទីជម្រក និងសត្វពាហនៈទាំងឡាយ ។

នៅចុងសប្ដាហ៍ បុរសទាំងពីររូបនោះបានត្រឡប់ទៅឯស្ថានីយរថភ្លើងវិញ ដើម្បីជិះរថភ្លើងត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ។ លោកតា ចន បានទទួលការបង់ប្រាក់នៅថ្ងៃនោះសម្រាប់ការធ្វើការរបស់គាត់ ហើយត្រូវបានឲ្យជាកាក់ប្រាក់ផេសូមួយកញ្ចប់ សម្រាប់ចំណាយលើការចំណាយផ្សេងៗទៀត ។ នៅពេលដែលបុរសទាំងពីររូបនោះបានបង់ប្រាក់ឲ្យ លោកតា ចន បានជូនប្រាក់ដែលនៅសល់ឲ្យទៅលោក ហាត់ វិញ ដែលធ្វើឲ្យគាត់មានការភ្ញាក់ផ្អើលដោយសារតែគាត់ពុំបានរំពឹងទុកថានឹងមានប្រាក់ខ្លះនៅសេសសល់នោះទេ ។ បុរសនោះបានសួរថាតើលោកតា ចន ពិតជាបានបង់លើការចំណាយទាំងអស់ដែរឬទេ ហើយលោកតា ចន បានឆ្លើយថា ចំណាយលើការធ្វើដំណើរទាំងអស់ត្រូវបានបង់រួចហើយ ហើយនេះជាប្រាក់ដែលនៅសេសសល់ ។

រថភ្លើងបានបន្លឺសម្លេងសារ៉ែន ។ លោក ហាត់ បានបែរខ្លួនដើម្បីរៀបចាកចេញទៅ ប៉ុន្តែគាត់បានងាកមកវិញ ហើយបានបោះស្បោងដែលមានកាក់ដ៏ធ្ងន់ឲ្យទៅលោកតា ចន ។ « ណេះ! សូមយកស្បោងនេះទៅឲ្យកូនប្រុសរបស់លោកចុះ » ។ លោកតា ចន បានចាប់យកស្បោងនោះ ហើយបានត្រឡប់មក កូឡូនៀ ជូរ៉េហ្ស វិញ ។ នៅល្ងាចនោះនៅពេលដែលសមាជិកគ្រួសារបាននៅជួបជុំគ្នា បន្ទាប់ពីបានឮដំណើររឿងដ៏អស្ចារ្យនោះ លោកតា ចន បាននឹកឃើញអំពីស្បោងនោះ ហើយក៏បានយកស្បោងនោះមកដាក់នៅលើតុ ។ លោកតា ចន បាននិយាយថា គាត់ពុំបានដឹងថា មានប្រាក់ប៉ុន្មាននៅក្នុងស្បោងនោះទេ

ដូច្នោះក៏បានចាក់ប្រាក់ទាំងនោះនៅលើតុដោយក្ដីត្រេកអរ ---គំនរប្រាក់នោះគឺមានទំហំធំណាស់ ហើយនៅពេលដែលរាប់ប្រាក់នោះ គឺប្រាក់នោះមានចំនួនដល់ទៅ 100 ផេសូជាប្រាក់ ។

ជាការពិតណាស់ដែលនោះ គឺជាពរជ័យដ៏ធំដែលលោក ហាត់ សម្រេចចិត្តដើម្បីធ្វើដំណើរនោះ ។ លោក ចន និងក្មេងប្រុសៗរបស់លោកបានរកបានចំណូលដ៏ល្អ ប៉ុន្តែប្រាក់ចំនួន 100 ផេសូដែលនៅសល់គឺជាការរំលឹកពីដង្វាយមួយភាគដប់តាមចំនួនដែលបានបង់កាលពីសប្ដាហ៍មុន ។ ចំពោះមនុស្សមួយចំនួនដំណើររឿងនេះប្រហែលជាការចៃដន្យដ៏គួរឲ្យចាប់អារម្មណ៍ ប៉ុន្តែចំពោះក្រុមគ្រួសាររបស់ វ៉េធិន វិញ វាគឺជាមេរៀនយ៉ាងច្បាស់មកអំពីព្រះអម្ចាស់ថា ទ្រង់ចងចាំពីការសន្យារបស់ទ្រង់ចំពោះអ្នកទាំងឡាយណាដែលបានបង់ប្រាក់ដង្វាយមួយភាគក្នុងដប់របស់ពួកគេ ។

កាលពីនៅក្មេង ខ្ញុំស្រឡាញ់ដំណើររឿងនោះណាស់ ពីព្រោះវាជារឿងការធ្វើដំណើរបោះជំរំលើខ្នងសេះទៅលើភ្នំ ដើម្បីបាញ់សត្វ និងស្ទូចត្រី ។ ហើយខ្ញុំស្រឡាញ់រឿងនេះពីព្រោះវាជារឿងដែលបង្រៀនថា នៅពេលយើងគោរពតាម យើងនឹងត្រូវបានប្រទានពរឲ្យ ។ មានកិច្ចការជាច្រើនដែលយើងទាំងអស់គ្នាអាចរៀនពីដំណើររឿងនៃការបង់ដង្វាយមួយភាគក្នុងដប់នេះ ។

ទីមួយ អ្នកនឹងបានដឹងថា ការបង់ដង្វាយមួយភាគក្នុងដប់នៅក្នុងករណីនេះ គឺមិនទាក់ទងទៅនឹងចំណូលជាសាច់ប្រាក់នោះទេ ។ ក្រុមគ្រួសាររបស់ វ៉េធិន បានសម្រេចចិត្តដើម្បីប្រើប្រាស់ប្រាក់ចំណូលដំបូងរបស់ពួកគេដើម្បីបង់ដង្វាយមួយភាគក្នុងដប់ ពីព្រោះពួកគេបានរស់នៅយ៉ាងល្អដោយសារតែសត្វពាហនៈ និងផលផ្លែឈើ ហើយនិងបន្លែផ្សេងៗរបស់ពួកគេនៅក្នុងសួន ។ ពួកគេពិតជាមានអារម្មណ៍ថាពួកគេបានជំពាក់ព្រះអម្ចាស់សម្រាប់ពរជ័យរបស់ពួកគេជាច្រើន ។

នោះគឺជាការរំលឹកពីការបញ្ជាក់នូវព្រះបន្ទូលរបស់ព្រះអម្ចាស់នៅពេលដែលទ្រង់បានសុំថា ៖ « គឺនៅក្នុងដង្វាយមួយភាគក្នុងដប់ ហើយក្នុងដង្វាយលើកចុះឡើងនោះឯង » (ម៉ាឡាគី 3:8 ) ។ ពិតណាស់ បងប្អូនប្រុសស្រីទាំងឡាយ គឺដូចជាលោក ចន និងអ៊ីដា វ៉េធិន បានដឹងថារដូវកាលនោះបានកន្លងផុតទៅក្ដី គឺយើងទាំងអស់គ្នាជំពាក់ដល់ព្រះអម្ចាស់ ។ សុំឲ្យយើងកុំតវ៉ាថាមិនបានកោងយករបស់ព្រះឡើយ ។ សូមឲ្យយើងបានស្មោះត្រង់ និងបង់បំណុលរបស់យើងទៅព្រះអម្ចាស់ ។ អ្វីដែលទ្រង់សុំវិញគឺគ្រាន់តែ 10 ភាគរយប៉ុណ្ណោះ ។

អ្វីបន្ទាប់ទៀតដែលខ្ញុំសំគាល់ឃើញអំពីដំណើររឿងនោះគឺថាជីដូនជីតារបស់ខ្ញុំបានបង់ដង្វាយមួយភាគក្នុងដប់ ដោយមិនគិតពីស្ថានភាពក្រីក្រនៃហិរញ្ញវត្ថុគ្រួសាររបស់លោកឡើយ ។ ពួកគេបានស្គាល់ពីព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ពួកគេបានប្រៀបប្រដូចបទគម្ពីរទាំងឡាយទៅនឹងខ្លួនរបស់ពួកគេផ្ទាល់ ( សូមមើល នីហ្វៃទី 1 19:23–24 ) ហើយធ្វើតាមក្រឹត្យវិន័យ ។ នេះហើយជាអ្វីដែលព្រះអម្ចាស់បានរំពឹងទុកចំពោះយើងទាំងអស់គ្នា ។ ទ្រង់បានរំពឹងទុកថាយើងទាំងអស់គ្នានឹងបង់ដង្វាយមួយភាគក្នុងដប់ មិនថានៅគ្រាដែលយើងមានច្រើន ឬមិនថាមានប្រាក់នៅ « សេសសល់ » ក្រោយពីបានបង់ចំណាយផ្សេងៗនោះទេ ប៉ុន្តែគឺដូចជាទ្រង់បានដាក់បញ្ជាតាំងពីបុរាណកាលមកថា ក្នុង « កូនដំបូង » ពីហ្វូងសត្វ ទោះជាតិច ឬច្រើនក្ដី ។ ព្រះអម្ចាស់បានដាក់បញ្ញត្តិថា « កុំឲ្យបង្អង់នឹងថ្វាយផលផ្លែ... ដំបូង » ឡើយ ( និក្ខមនំ 22:29 ) ។ រឿងនេះបានក្លាយជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំថា វិធីដ៏ជាក់លាក់បំផុតដើម្បីបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់គឺត្រូវបង់ភ្លាមៗនៅពេលដែលយើងទទួលបានចំណូល ។ ជាការពិតណាស់ ខ្ញុំបានសង្កេតឃើញថា នេះគឺជាវិធីតែមួយគត់ ។

យើងបានរៀនពីជីដូនជីតា វ៉េធិន របស់ខ្ញុំថា ដង្វាយមួយភាគក្នុងដប់គឺមិនសំខាន់ទៅលើថាតើប្រាក់ប៉ុន្មាននោះទេ វាសំខាន់ទៅលើ---សេចក្ដីជំនឿលើព្រះអម្ចាស់ ។ ទ្រង់បានសន្យានូវពរជ័យជាច្រើន ប្រសិនបើយើងគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ ពិតប្រាកដណាស់ ចន និង អ៊ីដា វ៉េធិន បានបង្ហាញសេចក្ដីជំនឿដ៏អស្ចារ្យនៅក្នុងការបង់ដង្វាយមួយភាគក្នុងដប់របស់ពួកគាត់ ។ សូមយើងបង្ហាញសេចក្ដីជំនឿរបស់យើងទៅលើព្រះអម្ចាស់តាមរយៈការបង់ដង្វាយមួយភាគក្នុងដប់របស់យើង ។ សូមបង់ដង្វាយមួយភាគក្នុងដប់មុនគេ សូមបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ ។ សូមបង្រៀនកូនចៅរបស់យើងឲ្យបង់ដង្វាយមួយភាគក្នុងដប់ សូមឲ្យបង់សូម្បីតែចេញពីប្រាក់វិភាជន៍របស់ពួកគេក្ដី ឬចំណូលរបស់ពួកគេ ហើយបន្ទាប់ពីនោះ សូមនាំពួកគេឲ្យចូលរួមនៅក្នុងការទូទាត់ប្រាក់ដង្វាយប្រចាំឆ្នាំ ដើម្បីឲ្យពួកគេបានឃើញពីគំរូ និងសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ ។

មានលទ្ធភាពមួយដែលអាចបកស្រាយខុសពីដំណើររឿងរបស់ជីដូនជីតារបស់ខ្ញុំ ។ មនុស្សម្នាក់អាចសន្មតថា ដោយសារតែយើងបង់ដង្វាយមួយភាគក្នុងដប់ជាសាច់ប្រាក់ នោះទើបព្រះអម្ចាស់នឹងតែងតែប្រទានពរមកវិញជាសាច់ប្រាក់ ។ កាលពីនៅវ័យក្មេងខ្ញុំចង់គិតបែបនោះ ។ ចាប់ពីពេលនោះមកខ្ញុំបានរៀនថា យើងមិនចាំបាច់បង់ជាប្រាក់នោះទេ ។ ព្រះអម្ចាស់សន្យាថានឹងប្រទានពរជ័យដល់អ្នកទាំងឡាយណាដែលបង់ដង្វាយមួយភាគក្នុងដប់របស់ពួក

គេ ។ ទ្រង់សន្យាថានឹង « បើក... ស្ថានសួគ៌ដើម្បីចាក់ព្រះពរមកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ » (ម៉ាឡាគី 3:10 ) ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ទ្រង់ឆ្លើយតបនឹងសេចក្ដីសន្យារបស់ទ្រង់ ហើយប្រសិនបើយើងស្មោះត្រង់ចំពោះការបង់ដង្វាយមួយភាគក្នុងដប់របស់យើង យើងនឹងមិនខ្វះអ្វីដែលចាំបាច់ក្នុងជីវិតរស់នៅទេ ប៉ុន្តែទ្រង់មិនសន្យាឲ្យមានទ្រព្យសម្បត្តិស្ដុកស្ដម្ភនោះទេ ។

ប្រាក់ និងគណនីធនាគារមិនមែនជាពរជ័យស្ដុកស្ដម្ភដែលទ្រង់បានសន្យានោះទេ ។ ទ្រង់ប្រទានពរជ័យដល់យើងជាប្រាជ្ញាដើម្បីគ្រប់គ្រងនូវពរជ័យផ្នែកខាងសម្ភាររបស់យើងដែលមានដែនកំណត់ ប្រាជ្ញាដែលធ្វើឲ្យយើងអាចរស់នៅប្រសើរឡើងដល់ 90 ភាគរយ នៃចំណូលរបស់យើងជាជាង 100 ភាគរយ ។ ខ្ញុំបានចាប់ផ្ដើមយល់ថាពរជ័យដ៏ស្ដុកស្ដម្ភរបស់ព្រះអម្ចាស់គឺជាពរជ័យខាងវិញ្ញាណ ហើយជាញឹកញាប់ពរជ័យនេះមានទាក់ទងទៅនឹងក្រុមគ្រួសារ មិត្តភ័ក្តិ និងដំណឹងល្អ ។

ជាញឹកញាប់ទ្រង់ហាក់ដូចជាប្រទានពរជ័យជាការដឹងជាពិសេសនូវឥទ្ធិពល និងការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ជាពិសេសបំផុតនោះគឺនៅក្នុងបញ្ហាអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារ ដូចជាការចិញ្ចឹមបីបាច់កូនចៅក្ដី ។ ការមានញាណដឹងខាងវិញ្ញាណនេះអាចជួយយើងរីករាយនឹងពរជ័យនៃសេចក្ដីសុខដុម និងសេចក្ដីសុខសាន្តនៅក្នុងគេហដ្ឋាន ។ ប្រធាន ជេមស៍ អ៊ី ហ្វោស្ត បានផ្ដល់ជាយោបល់ថាការបង់ដង្វាយមួយភាគក្នុងដប់គឺជាការធានារ៉ាប់រងយ៉ាងល្អប្រសើរដើម្បីប្រឆាំងទប់ទល់និងការលែងលះគ្នា។ ( សូមមើល James E. Faust « Enriching Your Marriage » *Liahona* និង *Ensign* ខែ មេសា ឆ្នាំ 2007 ទំព័រ 2–6 ) ។

ការបង់ដង្វាយមួយភាគក្នុងដប់ជួយយើងធ្វើការអភិវឌ្ឍន៍ការចេះស្ដាប់បង្គាប់ និងដួងចិត្តសុភាពរាបសា ហើយនិងដួងចិត្តដែលមានអំណរគុណដែលចេះ « ទទួលស្គាល់... ព្រះហស្តរបស់ទ្រង់ក្នុងគ្រប់ទាំងអស់ » ( គ. និង ស. 59:21 ) ។ ការបង់ដង្វាយមួយភាគក្នុងដប់លើកទឹកចិត្តយើងឲ្យមានសប្បុរសធម៌ និងចេះលះបង់ ហើយនិងចិត្តសប្បុរសដែលពោរពេញទៅដោយសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធរបស់ព្រះគ្រីស្ទ ។ យើងចាប់ផ្ដើមជាមនុស្សដែលមានចិត្តចង់បម្រើ និងប្រទានពរជ័យដល់អ្នកដទៃ ដោយមានដួងចិត្តចេះគោរពប្រតិបត្តិ ស្ដាប់បង្គាប់តាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ។

អ្នកបង់ដង្វាយមួយភាគក្នុងដប់ជាប្រចាំបានឃើញថាសេចក្ដីជំនឿរបស់ពួកគេនៅក្នុងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទត្រូវបានពង្រឹង និងអភិវឌ្ឍន៍យ៉ាងរឹងមាំដោយការប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ទ្រង់ និងសាសនាចក្ររបស់ទ្រង់ ។ ពរជ័យទាំងនេះគ្មានទំនាក់ទំនងនឹងប្រាក់ ឬសម្ភារ តាមបែបណាមួយឡើយ ប៉ុន្តែពិតប្រាកដណាស់ ពួកគេមាននូវពរជ័យដ៏មានតម្លៃទាំងឡាយរបស់ព្រះអម្ចាស់ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា កាលណាយើងបង់ដង្វាយមួយភាគក្នុងដប់របស់យើងដោយស្មោះត្រង់ នោះព្រះអម្ចាស់នឹងបើកទ្វារស្ថានសួគ៌ ហើយចាក់ព្រះពរដ៏មហិមាបំផុតមកលើយើង ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។